**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៤ អនក្រ.បក

# អនុក្រឹត្យ

# ស្ដីពី

# ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដី ចំនួន០៣ទីតាំង ទំហំសរុប ១៣៣.៧២៤ ម² (មួយរយសាមសិបបីពាន់ប្រាំពីររយម្ភៃប្រាំបួន ម៉ែត្រក្រឡា) ស្ថិតក្នុងសង្កាត់គោករកា និងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ដីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ទំហំ៣.២៣៩,៧ហិកតា

ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្នុងនោះរួមមាន៖

- ទីតាំងទី១. មានផ្ទៃដី ទំហំ ៦៤.៥២៤ ម$^{២}$ (ហុកសិបបួនពាន់ ប្រាំរយម្ភៃបួន ម៉ែត្រក្រឡា) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី២. មានផ្ទៃដី ទំហំ ៥៩.៤០១ ម$^{២}$ (ហាសិបប្រាំបួនពាន់ បួនរយមួយ ម៉ែត្រក្រឡា) ស្ថិតនៅភូមិត្រពាំងពោធិ៍ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ)។
- ទីតាំងទី៣. មានផ្ទៃដី ទំហំ ៩.៨០៤ ម$^{២}$ (ប្រាំបួនពាន់ ប្រាំបីរយបួន ម៉ែត្រក្រឡា) ស្ថិតនៅភូមិព្រៃស្វាយ សង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ)។

**មាត្រា ២**: ត្រូវបានធ្វើប្រទានកម្មផ្ទៃដី ចំនួន០៣ទីតាំង ទំហំសរុប ១៣៣.៧២៩ ម$^{២}$ (មួយរយសាមសិបបីពាន់ ប្រាំពីររយម្ភៃប្រាំបួន ម៉ែត្រក្រឡា) ស្ថិតក្នុងសង្កាត់គោករកា និងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូន លោក ឡាញ់ ភាវ៉ា ដោយពន្ធ និងអាករផ្សេងៗ ជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣**: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៣ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែមករា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៤*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

គំនូសប្លង់បន្ទាញដីចំនួន ០៣ ទីតាំង សរុបទំហំៈ ១៣៣,៧២៩ (មួយរយសាមសិបបីពាន់ ប្រាំពីររយម្ភៃប្រាំបួន) ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់គោករកា និងសង្កាត់ពន្សាំង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ
ដែលស្នើសុំធ្វៀលចេញពីអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ និងធ្វើប្រទានកម្មជូនលោក ឡាញ់ ភាព ដើម្បីគ្រប់គ្រងកម្មសិទ្ធិ




① និយាមកា (ភូមិព្រពាំងពោធិ៍)

| ID | X | Y |
|---|---|---|
| 1 | 477099.522 | 1284849.093 |
| 2 | 477253.132 | 1284678.763 |
| 3 | 477205.017 | 1284693.060 |
| 4 | 477176.244 | 1284674.208 |
| 5 | 477153.083 | 1284644.490 |
| 6 | 477154.233 | 1284623.657 |
| 7 | 476961.120 | 1284641.328 |
| 8 | 476895.312 | 1284736.287 |
| 9 | 476856.774 | 1284792.106 |
| 10 | 476849.993 | 1284801.929 |
| 11 | 476872.874 | 1284806.813 |
| 12 | 476861.821 | 1284840.834 |
| 13 | 476883.543 | 1284847.931 |
| 14 | 477051.177 | 1284902.699 |

② និយាមកា (ភូមិព្រពាំងពោធិ៍)

| ID | X | Y |
|---|---|---|
| 1 | 477155.347 | 1284603.471 |
| 2 | 477161.007 | 1284500.926 |
| 3 | 477143.709 | 1284289.859 |
| 4 | 476992.697 | 1284302.086 |
| 5 | 476984.579 | 1284203.124 |
| 6 | 476959.049 | 1284205.214 |
| 7 | 476925.000 | 1284208.000 |
| 8 | 476938.000 | 1284306.000 |
| 9 | 476939.597 | 1284311.935 |
| 10 | 476982.039 | 1284469.710 |
| 11 | 476989.685 | 1284469.999 |
| 12 | 477020.798 | 1284477.840 |
| 13 | 477018.242 | 1284510.571 |
| 14 | 477016.659 | 1284572.048 |
| 15 | 476989.262 | 1284604.309 |
| 16 | 476976.184 | 1284619.866 |
| 17 | 477131.466 | 1284605.656 |

③ និយាមកា (ភូមិព្រៃស្វាយ)

| ID | X | Y |
|---|---|---|
| 1 | 475523.363 | 1283990.135 |
| 2 | 475519.430 | 1284003.585 |
| 3 | 475515.375 | 1284026.805 |
| 4 | 475550.185 | 1284033.046 |
| 5 | 475583.562 | 1284039.447 |
| 6 | 475622.629 | 1284041.579 |
| 7 | 475661.042 | 1284044.758 |
| 8 | 475668.868 | 1284042.658 |
| 9 | 475697.184 | 1284041.579 |
| 10 | 475697.954 | 1284085.164 |
| 11 | 475730.960 | 1284081.218 |
| 12 | 475704.384 | 1284000.629 |
| 13 | 475694.023 | 1283996.898 |